## <u>សេចក្តីថ្លែងការណ៍រួម</u>

រាជធានីភ្នំពេញ ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១៧

# អង្គការសង្គមស៊ីវិល សូមចូលរួមអបអរសាទរដល់កោះតៃវ៉ាន់ដែលតុលាការជាន់ខ្ពស់បានសម្រេចគាំទ្រភាពស្មើគ្នាក្នុងការរៀបអាពាហ៍ពិពាហ៍ភេទដូចគ្នា និងអំពាវនាវឱ្យមានច្បាប់ទទួលស្គាល់អាពាហ៍ពិពាហ៍ភេទដូចគ្នានៅកម្ពុជា

យើងខ្ញុំជាអង្គការសង្គមស៊ីវិល (“សង្គមស៊ីវិល”) ដែលមានរាយនាមដូចខាងក្រោម សូមចូលរួមអបអរសាទរដល់ប្រជាជននៃកោះតៃវ៉ាន់ ហើយជាពិសេសសហគមន៍អ្នកស្រឡាញ់ភេទដូចគ្នា ស្រីស្រឡាញ់ស្រី បុរសស្រឡាញ់បុរស អ្នកស្រឡាញ់ទាំងពីរភេទ អន្តរភេទ និងអ្នកដែលមិនកំណត់អត្តសញ្ញាណ (“អ្នកស្រឡាញ់ភេទដូចគ្នា”) ទាក់ទងទៅនឹងសេចក្តីសម្រេចរបស់តុលាការធម្មនុញ្ញនៃកោះតៃវ៉ាន់ដែលបានចេញនៅថ្ងៃទី២៤ ខែឧសភា ដែលបានធ្វើឱ្យកោះតៃវ៉ាន់ក្លាយជាដែនដីដំបូងគេនៅអាស៊ីដែលទទួលស្គាល់អាពាហ៍ពិពាហ៍ភេទដូចគ្នាតាមផ្លូវច្បាប់ ។

នៅក្នុងសេចក្តីសម្រេចរបស់ខ្លួន តុលាការធម្មនុញ្ញបានសម្រេចថាច្បាប់ដែលមានស្រាប់ដែលមិនអនុញ្ញាតឱ្យអ្នកស្រឡាញ់ភេទដូចគ្នារៀបអាពាហ៍ពិពាហ៍គឺអធម្មនុញ្ញភាព និងរំលោភបំពានសិទ្ធិមនុស្សជាមូលដ្ឋាន។ សេចក្តីសម្រេចនេះបានចែងថាការហាមប្រាមអាពាហ៍ពិពាហ៍ភេទដូចគ្នា គឺ ‘កំហុសឆ្គងផ្នែកច្បាប់យ៉ាងធ្ងន់ធ្ងរ’ និង ‘មិនស្របគ្នាជាមួយនឹងស្មារតី និងអត្ថន័យនៃសេរីភាពអាពាហ៍ពិពាហ៍’ ព្រមទាំង ‘សិទ្ធិស្មើភាពគ្នា’។[1]

នៅក្នុងសេចក្តីសម្រេចដ៏សំខាន់នេះ កោះតៃវ៉ាន់ក្លាយជាអ្នកត្រួសត្រាយក្នុងការគោរពសិទ្ធិអ្នកស្រឡាញ់ភេទដូចគ្នានៅក្នុងតំបន់អាស៊ី ដែលជាការផ្តល់សន្ទុះថ្មីមួយទៀតសម្រាប់ការទាមទារសមភាពអាពាហ៍ពិពាហ៍នៅទូទាំងទ្វីបផងដែរ។ យើងខ្ញុំ ជាអង្គការសង្គមស៊ីវិល សូមយកឱកាសជាប្រវត្តិសាស្ត្រនេះដើម្បីអំពាវនាវដល់រាជរដ្ឋាភិបាលកម្ពុជា (“រដ្ឋាភិបាល”) ដើម្បីបង្ហាញនូវការប្តេជ្ញាចិត្តរបស់ខ្លួនចំពោះសិទ្ធិអ្នកស្រឡាញ់ភេទដូចគ្នា តាមរយៈការបង្កើតច្បាប់ទទួលស្គាល់អាពាហ៍ពិពាហ៍ភេទដូចគ្នានៅកម្ពុជា។

មាត្រា២៤ នៃគោលការណ៍យ៉កយ៉ាកាតា ស្តីពីគោលការណ៍នៃការអនុវត្តច្បាប់សិទ្ធិមនុស្សអន្តរជាតិស្តីពីនិន្នាការភេទ និងអត្តសញ្ញាណយេនឌ័រ (“គោលការណ៍យ៉កយ៉ាកាតា”) បញ្ជាក់បន្ថែមថាបុគ្គលគ្រប់រូបមានសិទ្ធិក្នុងការកសាងគ្រួសារ ដោយមិនគិតពីនិន្នាការភេទ ឬអត្តសញ្ញាណយេនឌ័រ/ការបង្ហាញនូវទំនោរយេនឌ័រ (“សូជី”) និងអំពាវនាវដល់រដ្ឋភាគីទាំងអស់ឱ្យចាត់វិធានការតាមផ្លូវច្បាប់ដើម្បីធានាថាអាពាហ៍ពិពាហ៍ភេទដូចគ្នាត្រូវបានទទួល

---

[1] តុលាការធម្មនុញ្ញនៃសាធារណរដ្ឋចិន (កោះតៃវ៉ាន់), ‘សេចក្តីប្រកាសព័ត៌មានស្តីពីសំណុំរឿងអាពាហ៍ពិពាហ៍ភេទដូចគ្នា’, (ថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០១៧) <http://bit.ly/2rFTIeL>

ស្គាល់យ៉ាងពេញលេញ។[2] ខណៈពេលដែលគោលការណ៍នេះមិនចងជាកាតព្វកិច្ចផ្លូវច្បាប់ គោលការណ៍យ៉កយ៉ាកាតាបញ្ជាក់អំពីរបៀបដែលច្បាប់សិទ្ធិមនុស្សអន្តរជាតិដែលចងជាកាតព្វកិច្ចផ្លូវច្បាប់ ត្រូវអនុវត្តទាក់ទិននឹងបញ្ហានិន្នាការភេទ និងអត្តសញ្ញាណយេនឌ័រ ។ បច្ចុប្បន្ននេះ ក្របខ័ណ្ឌច្បាប់កម្ពុជានៅមិនទាន់បំពេញតាមបទដ្ឋាន ដែលមានចែងក្នុងគោលការណ៍យ៉កយ៉ាកាតានេះនៅឡើយទេ។ មាត្រា៤៥ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា កំណត់ថា អាពាហ៍ពិពាហ៍ត្រូវធ្វើតាមល័ក្ខខ័ណ្ឌដែលមានចែងក្នុងច្បាប់ និងតាមគោលការណ៍ស្ម័គ្រចិត្ត 'ប្តីមួយ ប្រពន្ធមួយ' ហើយជាលក្ខណៈទ្រឹស្តីចំណុចនេះមិនបានរាប់បញ្ចូលអ្នកស្រឡាញ់ភេទដូចគ្នានៅក្នុងការរៀបអាពាហ៍ពិពាហ៍ជាមួយគ្នានោះទេ។ ទោះជាយ៉ាងណាក្តី ហាក់ដូចជាការលើកទឹកចិត្តដែរដែលក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ បានជំនួស និងនិរាករណ៍ច្បាប់ពីមុនដែលបានហាមឃាត់យ៉ាងជាក់លាក់លើអាពាហ៍ពិពាហ៍ភេទដូចគ្នា។ ប្រការនេះជាបោះជំហានមួយក្នុងទិសដៅដ៏ត្រឹមត្រូវឆ្ពោះទៅរកសមភាពអាពាហ៍ពិពាហ៍ តែយ៉ាងណាក៏ដោយក៏នៅតែតម្រូវឱ្យមានវិធានការផ្នែកច្បាប់ជាក់លាក់សម្រាប់ការទទួលស្គាល់សិទ្ធិនេះនៅក្នុងប្រទេសកម្ពុជា។

មន្ត្រីជាន់ខ្ពស់មួយចំនួនរបស់រដ្ឋាភិបាលកម្ពុជា បានសម្តែងការគាំទ្ររបស់ខ្លួនចំពោះសិទ្ធិអ្នកស្រឡាញ់ភេទដូចគ្នា ដោយមានមន្ត្រីម្នាក់អះអាងថាសមភាពអាពាហ៍ពិពាហ៍ គឺត្រូវបានធានារួចហើយតាមច្បាប់៖ នៅថ្ងៃទី ២៣ ខែកញ្ញា ឆ្នាំ២០១៥ លោក ផៃ ស៊ីផាន អ្នកនាំពាក្យទីស្តីការគណៈរដ្ឋមន្ត្រីបានថ្លែងថា "*គ្មានច្បាប់កម្ពុជាណា រើសអើងប្រឆាំងនឹង [អ្នកស្រឡាញ់ភេទដូចគ្នា] នោះទេ ហើយក៏គ្មានអ្វីហាមឃាត់អ្នកទាំងនោះស្រឡាញ់គ្នា ឬរៀបការដែរ*"។[3] បើទោះបីជាស្ថានភាពផ្នែកច្បាប់នៅតែមិនទាន់មានភាពច្បាស់លាស់ក៏ដោយ តែពេលវេលាហាក់ដូចជាបានមកដល់ហើយសម្រាប់ប្រទេសកម្ពុជាដើម្បីធ្វើឱ្យដូចកោះតៃវ៉ាន់ និងប្រទេសចំនួន ២២ ផ្សេងទៀតនៅជុំវិញ ពិភពលោកដែលបានផ្តល់សិទ្ធិយ៉ាងច្បាស់លាស់ដល់ប្រជាពលរដ្ឋរបស់ខ្លួនក្នុងការរៀបអាពាហ៍ពិពាហ៍។

សហគមន៍អ្នកស្រឡាញ់ភេទដូចគ្នានៅកម្ពុជាប្រឈមនឹងបញ្ហាចម្បងៗមួយចំនួនដោយសារតែភាពមិនស្មើគ្នាចំពោះការរៀបអាពាហ៍ពិពាហ៍។ នៅក្នុងប្រទេសកម្ពុជា ក្រុមគ្រួសារនៅប្រកាន់ខ្ជាប់ទំនៀមទម្លាប់ផ្នែកវប្បធម៌ និងដើរតួនាទីសំខាន់នៅក្នុងសង្គម។ ការបដិសេធសិទ្ធិក្នុងការរៀបអាពាហ៍ពិពាហ៍របស់គូស្រករដែលជាអ្នកស្រឡាញ់ភេទដូចគ្នាបង្កើតបានជាទម្រង់មួយនៃភាពឯកោក្នុងសង្គម និងវប្បធម៌ ព្រមទាំងកាត់ផ្តាច់អ្នកទាំងនោះចេញពីសហគមន៍ផ្ទាល់របស់ពួកគេផងដែរ។ សហគមន៍អ្នកស្រឡាញ់ភេទដូចគ្នាគឺមិនត្រឹមតែត្រូវបានហាមឃាត់ពីការកសាងក្រុមគ្រួសារនោះទេ ប៉ុន្តែក៏ត្រូវបានបដិសេធសិទ្ធិផ្សេងៗដែលត្រូវទទួលបានតាមរយៈការរៀបអាពាហ៍ពិពាហ៍ផងដែរ ។ សិទ្ធិទាំងនេះរួមមានសុវត្ថិភាពខាងទ្រព្យសម្បត្តិ ការការពារពីការរំលោភបំពានក្នុងគ្រួសារ សិទ្ធិជាឪពុកម្តាយ និង

---

[2] គណៈកម្មការអ្នកច្បាប់អន្តរជាតិ ("គ.ច.អ") 'គោលការណ៍យ៉កយ៉ាកាតា ស្តីពីការអនុវត្តច្បាប់សិទ្ធិមនុស្សអន្តរជាតិទាក់ទងទៅនឹងនិន្នាការភេទ និងអត្តសញ្ញាណយេនឌ័រ' (ថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១៧) <https://goo.gl/aGIJ0U>

[3] ជា តាគីរូ 'អ្នកនាំពាក្យរដ្ឋាភិបាលមានប្រសាសន៍ថា ប្រទេសកម្ពុជាស្វាគមន៍អាពាហ៍ពិពាហ៍ភេទដូចគ្នា', *ខ្មែរថាមស៍* (ថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ ២០១៥)<http://bit.ly/1KVogxH>

ការអនុគ្រោះពន្ធ ជាដើម។ ស្ថានភាពបែបនេះក៏ធ្វើឱ្យប្រជាពលរដ្ឋកម្ពុជាដែលជាអ្នកស្រឡាញ់ភេទដូចគ្នាប្រឈមនឹងហានិភ័យចំពោះការរៀបអាពាហ៍ពិពាហ៍ជាមួយភេទផ្ទុយគ្នា ដែលជាការបង្ខំពីសំណាក់ក្រុមគ្រួសាររបស់ពួកគេផងដែរ។ របាយការណ៍ឆ្នាំ ២០១៦ របស់មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា ("ម.ស.ម.ក") បានបង្ហាញថា ៥៣%នៃស្ត្រីប្តូរភេទត្រូវបានឪពុកម្តាយរបស់ពួកគេចាប់បង្ខំឱ្យរៀបអាពាហ៍ពិពាហ៍។[4] របាយការណ៍ដែលចេញផ្សាយដោយសហគមន៍ឥន្ទធនូកម្ពុជា ("រ៉ក់") បានរកឃើញថា ៨២%នៃប្រជាពលរដ្ឋកម្ពុជាដែលជាអ្នកស្រឡាញ់ភេទដូចគ្នាយល់ថាភាពស្មើគ្នាក្នុងការរៀបអាពាហ៍ពិពាហ៍គឺជាអាទិភាពមួយនៅក្នុងការលើកកម្ពស់ជីវភាពរស់នៅរបស់ខ្លួន។[5]

នៅក្នុងប្រទេសកម្ពុជា ក៏ដូចជាបណ្តាប្រទេសជាច្រើននៅលើពិភពលោក ការទទួលស្គាល់ក្រុមអ្នកស្រឡាញ់ភេទដូចគ្នាមានភាពប្រសើរឡើង។ របាយកាណ៍របស់រ៉ក់ដែលបានលើកឡើងខាងលើបានបង្ហាញថា ៨៦%នៃប្រជាពលរដ្ឋកម្ពុជាដែលជាអ្នកស្រឡាញ់ភេទដូចគ្នាជឿថា សង្គមកម្ពុជាគឺកាន់តែបើកទូលាយចំពោះសហគមន៍របស់ពួកគេច្រើនជាងកាលពីបីទៅប្រាំឆ្នាំមុន។[6] បច្ចុប្បន្ននេះ ជាឱកាសសម្រាប់កម្ពុជាក្នុងការចូលរួមជាមួយកោះតៃវ៉ាន់ដើម្បីក្លាយជាអ្នកដឹកនាំពិភពលោកមួយទាក់ទិននឹងការគោរពសិទ្ធិអ្នកស្រឡាញ់ភេទដូចគ្នា តាមរយៈការបង្កើតច្បាប់ទទួលស្គាល់សមភាពអាពាហ៍ពិហ៍ និងសិទ្ធិស្មើគ្នាសម្រាប់ប្រជាពលរដ្ឋកម្ពុជាដែលជាអ្នកស្រឡាញ់ភេទដូចគ្នា។

យើងខ្ញុំ ជាអង្គការសង្គមស៊ីវិល សូមបញ្ជាក់ពីការអបអរសាទររបស់យើងខ្ញុំចំពោះប្រជាជននៃកោះតៃវ៉ាន់ និងសូមអំពាវនាវទៅដល់រដ្ឋាភិបាលកម្ពុជាចាត់វិធានការចាំបាច់ដើម្បីឆ្ពោះទៅរកភាពស្មើគ្នានៃការរៀបអាពាហ៍ពិពាហ៍សម្រាប់ប្រជាពលរដ្ឋកម្ពុជាដែលជាអ្នកស្រឡាញ់ភេទដូចគ្នា។

**សេចក្តីថ្លែងការណ៍រួមនេះ គាំទ្រដោយអង្គការសង្គមស៊ីវិលមាននាមដូចខាងក្រោម ៖**

**សហគមន៍**

១. សហគមន៍កោះស្រឡៅ (កោះកុង)
២.សហគមន៍ថ្មដា (ពោធិ៍សាត់)
៣.សាលាសមាគមសន្តិភាពកំពង់ស្ពឺ (កំពង់ស្ពឺ)
៤.សហគមន៍ផ្លូវរថភ្លើងទួលសង្កែ B (ភ្នំពេញ)

---

[4] មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា ("ម.ស.ម.ក"), *'ការរើសអើងលើអ្នកប្តូរភេទជាស្ត្រីនៅតាមទីប្រជុំជនក្នុងព្រះរាជាណាចក្រកម្ពុជា'* (របាយការណ៍) (ខែកញ្ញា ឆ្នាំ២០១៦) <http://bit.ly/2mu3kDV>

[5] សហគមន៍ឥន្ទធនូកម្ពុជា និង ថេល៍ ណែលសិន សូហ្វេសហ៍ កម្ពុជា ("ក្រុមជី អិន អេស"), 'ផ្នត់គំនិត អត្តចរិក និងអាកប្បកិរិយាចំពោះប្រជាជនដែលជាអ្នកស្រឡាញ់ភេទដូចគ្នានៅកម្ពុជា" (ខែធ្នូ ឆ្នាំ២០១៥) <http://bit.ly/2qCMipl>

[6] សហគមន៍ឥន្ទធនូកម្ពុជា, 'ផ្នត់គំនិត អត្តចរិក និងអាកប្បកិរិយា'

៥.សហគមន៍ផ្លូវរថភ្លើងទួលសង្កែ A (ភ្នំពេញ) (ភ្នំពេញ)

៦.សហគមន៍ភូមិ២៣ (ភ្នំពេញ)

៧.សហគមន៍ដីធ្លី ភូមិស្ពួន ខេត្តសៀមរាប (សៀមរាប)

៨.សហគមន៍ដីធ្លី ភូមិគ្រួស ខេត្តបាត់ដំបង (បាត់ដំបង)

៩.សហគមន៍ដីធ្លីរាជសីហ៍សាមគ្គីភាព ភូមិរំចេក បាត់ដំបង (បាត់ដំបង)

១០.យុវជនជនជាតិដើមភាគតិច ឃុំប្រមេ ស្រុកត្បែងមានជ័យខេត្តព្រះវិហារ (ព្រះវិហារ)

១១.សហគមន៍ដីធ្លី ភូមិព្រែកជីក ឃុំជីខក្រោម ខេត្តកោះកុង (កោះកុង)

១២.សហគមន៍ដីធ្លីភូមិ ១ ក្រុងព្រះសីហនុ (ក្រុងព្រះសីហនុ)

១៣.សហគមន៍ SOS ព្រលានយន្តហោះអន្តរជាតិភ្នំពេញ (ភ្នំពេញ)

១៤.សហគមន៍បឹងឈូក (ភ្នំពេញ)

១៥.សហគមន៍អតីតបណ្ណាញស្ត្រីបឹងកក់ (ភ្នំពេញ)

១៦.សហគមន៍បឹងប្រាំ (បាត់ដំបង)

១៧.សហគមន៍ឡពាង (កំពង់ឆ្នាំង)

**អង្គការសង្គមស៊ីវិលៈ**

១៨.សមាគមប្រជាធិបតេយ្យឯករាជ្យនៃសេដ្ឋកិច្ចក្រៅប្រព័ន្ធ (IDEA)

១៩.សមាគមឥន្ទ្រទេវី (IDA)

២០.ក្រុមការងារដើម្បីដោះស្រាយទំនាស់ (ACT)

២១.សហព័ន្ធកម្មករក្នុងវិស័យសេវាកម្ម និងចំណីអាហារកម្ពុជា (CFSWF)

២២.សម្ព័ន្ធសហជីពចលនាកម្មករ (CUMW)

២៣.បណ្តុំអ្នកស្រឡាញ់ភេទដូចគ្នានៅអាស៊ាន(ASC)

២៤.សមាគមមន្រ្តីរាជការឯករាជ្យកម្ពុជា (CICA)

២៥.ស្ម័គ្រចិត្តដើម្បីសង្គម (CVS)

២៦.សមាគមអាដហុក ការពារសិទ្ធិមនុស្ស និងអភិវឌ្ឍន៍នៅកម្ពុជា (ADHOC)

២៧.សម្ព័ន្ធខ្មែរជំរឿន និងការពារសិទ្ធិមនុស្ស លីកាដូ (LICADHO)

២៨.ជំនួយផ្នែកច្បាប់នៃកម្ពុជា (LAC)

២៩.មជ្ឈមណ្ឌលអប់រំច្បាប់សម្រាប់សហគមន៍ (CLEC)

៣០.អង្គការខេមរា (KHEMARA)

៣១.មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា (CCHR)

៣២.សហគមន៍ឥន្ទធនូកម្ពុជា (RoCK)
៣៣.អង្គការសកម្មភាពផ្សព្វផ្សាយដើម្បីការអប់រំ និងអភិវឌ្ឍន៍ (MEDIA One)
៣៤.អង្គការសុខភាពបុរសកម្ពុជា (MHC)
៣៥.អង្គការសេវាសង្គមសុខភាពបុរស (MHSS)
៣៦.អង្គការយេនឌ័រ និងអភិវឌ្ឍន៍នៅកម្ពុជា (GADC)
៣៧.អង្គការខាណា (KHANA)
៣៨.សម្ព័ន្ធសហជីពកម្ពុជា(CATU)
៣៩.សហព័ន្ធសហជីពកម្មករសំណង់និងព្រៃឈើកម្ពុជា (BWTUC)
៤០.សហព័ន្ធបុគ្គលិកទេសចរកម្ពុជា (CTSWF)
៤១.សម្ព័ន្ធសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរកម្ពុជា (CCAWDU)
៤២.អង្គការជនជាតិដើមភាគតិចកម្ពុជា (CIPO)
៤៣.អង្គការមាតាធម្មជាតិ (MN)